ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**************

សាលាឧទ្ធរណ៍ភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌ

លេខ: ២៤០/ ១៩.៣.២០១២

សាលដីកា

លេខ: ០១ ក្រ।।।ស/២៨.០១.២០១៤

# តាងនាមប្រជារាស្ត្រខ្មែរ

# សាលាឧទ្ធរណ៍ភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៤ ដោយមានសមាសភាពដូចតទៅ:

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ជាប្រធាន

លោកស្រី [redacted] ជាចៅក្រមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជី**

កញ្ញា [redacted]

ដើម្បីធ្វើការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ នៃសំណុំរឿងព្រហ្មទណ្ឌលេខ ២៤០ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១០ រវាង ៖

ជនជាប់ចោទឈ្មោះ [redacted] ហូសាន់ ភេទប្រុស អាយុ៣៦ឆ្នាំ ជាតិខ្មែរ មុខរបរៈកម្មករ កើតនៅ ភូមិចៀស ឃុំថ្មពេជ្រ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ទីលំនៅមុនចាប់ខ្លួន [redacted] ក្រុងព្រះវិហារ ខេត្តព្រះវិហារ ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (ស) ប្រពន្ធឈ្មោះ [redacted] មានកូន០២នាក់ ទោសពីមុនគ្មាន ចាប់ខ្លួនថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០, ឃុំខ្លួនថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១០។

មានមេធាវីការពារលោក [redacted] វិបុល។

<u>ជាប់ចោទពីបទ:</u> សមគំនិតក្នុងអំពើឃាតកម្មគិតទុកជាមុន ប្រព្រឹត្តនៅផ្សារកំពង់ប្រណាក ក្រុងព្រះវិហារ ខេត្តព្រះវិហារ កាលពីថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១០ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឲ្យផ្តន្ទាទោស តាមមាត្រា៦៩ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលនិងមាត្រា៣ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចាន់ធី ភេទស្រី អាយុ៥១ឆ្នាំ ជាតិខ្មែរ មុខរបរៈមេផ្ទះ បច្ចុប្បន្នរស់នៅ ភូមិកណ្តាល សង្កាត់កំពង់ប្រណាក ក្រុងព្រះវិហារ ខេត្តព្រះវិហារ។៤

## ឯដំណើររឿងមានដូចតទៅ ៖

កាលពីថ្ងៃទី១៦ខែកក្កដា ឆ្នាំ២០១០ វេលាម៉ោងប្រមាណ៦ និង៣០នាទី មានករណីប្លន់ប្រដាប់អាវុធ ស្ថិតនៅចំណុចផ្សារកំពង់ប្រណាក ភូមិកណ្តាល សង្កាត់កំពង់ប្រណាក ក្រុងព្រះវិហារ ខេត្តព្រះវិហារ ដែលបង្កឡើងដោយជនល្មើសឈ្មោះ [redacted] ប៊ុណ្ណា និងឈ្មោះ [redacted] ប៊ុណ្ណែ ហៅ [redacted] ហូសាន់ និងបក្សពួកបានប្លន់ទៅលើឈ្មោះ [redacted] គឹមហឿន ភេទប្រុស ដោយបានបាញ់ ចំនួន០២គ្រាប់បណ្តាលឲ្យស្លាប់ នៅនឹងកន្លែងកើតហេតុ។

បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ៦៨ ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១១ របស់សាលាដំបូងខេត្តព្រះវិហារ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ:

១- សម្រេចផ្តន្ទាទោសដាក់ពន្ធនាគារលើឈ្មោះ [redacted] ប៊ុណ្ណា ភេទប្រុស អាយុ៣៦ឆ្នាំ, ឈ្មោះ [redacted] ធី ភេទប្រុស ម្នាក់កំណត់ចំនួន១៥ឆ្នាំ ពីបទ ឃាតកម្មគិតទុកជាមុន (ប្លន់សំលាប់),

- សម្រេចផ្តន្ទាទោសដាក់ពន្ធនាគារលើឈ្មោះ [redacted] ហូសាន់ ហៅ [redacted] ប៊ុណ្ណែ ភេទប្រុស អាយុ៣៦ឆ្នាំ កំណត់ចំនួន១០ឆ្នាំ ពីបទ សមគំនិតក្នុងបទប្លន់ បានប្រព្រឹត្តនៅ ផ្សារកំពង់ប្រណាក ក្រុងព្រះវិហារ ខេត្តព្រះវិហារ កាលពីថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១០ បទល្មើសព្រហ្មទណ្ឌមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា ០៣ និងមាត្រា០៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

- អោយឈ្មោះ [redacted] គ្រីយ៉ា ភេទប្រុស អាយុ៣៨ឆ្នាំ រួចផុតពីបទចោទ ពីបទ សមគំនិត និងបទ ប្លន់ ប្រព្រឹត្តនៅ ផ្សារកំពង់ប្រណាក ក្រុងព្រះវិហារ ខេត្តព្រះវិហារ កាលពីថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១០។

២- បង្គាប់ឲ្យភ្នាក់ងារមានសមត្ថកិច្ច ស្វែងរកចាប់ខ្លួនឈ្មោះ [redacted] ប៊ុណ្ណា និងឈ្មោះ [redacted] ធី តាមអំណាចសាលក្រមនេះ។

បានឃើញបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១១ របស់ឈ្មោះ [redacted] ហូសាន់ ជាជនជាប់ចោទប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៦៨ ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១១ របស់សាលាដំបូងខេត្តព្រះវិហារ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច។

## នាពេលសវនាការ

ប្រធានក្រុមប្រឹក្សា បញ្ជាក់អង្គហេតុរឿងជូនអង្គសវនាការ

ក្រឡាបញ្ជីអានចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចាន់ធី ឆ្លើយនៅសាលាដំបូងខេត្តព្រះវិហារ។

ជនជាប់ចោទឈ្មោះ [redacted] ហូសាន់ ឆ្លើយថា មុនថ្ងៃកើតហេតុ បងខ្លួនឈ្មោះ [redacted] ប៊ុណ្ណា បានបបួលខ្លួនធ្វើសកម្មភាពប្លន់មែន តែខ្លួនមិនព្រម គាត់ក៏ទៅបបួលអ្នកផ្សេង។ នៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១០ ជាថ្ងៃកើតហេតុ បងខ្លួន និងឈ្មោះ [redacted] ធី ជិះម៉ូតូឌុបគ្នាទៅផ្សារ ឯខ្លួនជិះម៉ូតូខ្លួនតែម្នាក់ឯងទេ។ លុះទៅដល់ផ្សារ បងខ្លួនឲ្យខ្លួននៅចាំម៉ូតូ ហើយពួកគេទាំងពីរ នាំគ្នាដើរចូលទៅក្នុងផ្សារ។ នៅពេលពួកគេត្រឡប់មកវិញ ខ្លួន

ឃើញគេកាន់ចង់ខ្មៅ ទើបខ្លួនដឹងថា ពួកបងខ្លួនប្លន់គេ។ ក្រោយការប្លន់បានហើយ [redacted] ប៊ុណ្ណា បានឲ្យប្រាក់ខ្លួនចំនួន ៤.០០០.០០០រៀល ជាប្រាក់បានមកពីការលក់ទ្រព្យដែលប្លន់បាន។ សំណូមពរ សុំឲ្យលោកប្រធានមេត្តាបន្ធូបន្ថយទោសឲ្យខ្លួន បានឆាប់ចេញពីពន្ធនាគារ។

## សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

ជនជាប់បានទទួលស្គាល់កំហុសថា ខ្លួនពិតជាបានចូលរួមប្រព្រឹត្តពិតមែន, តំណាងមហាអយ្យការយល់ឃើញថា សេចក្តីសម្រេចរបស់សាលាដំបូងខេត្តព្រះវិហារ សម្រេចត្រឹមត្រូវ តែទណ្ឌកម្មទាបពេកហើយ, ដោយក្នុងរឿងនេះ បណ្តឹងឧទ្ធរណ៍ជារបស់ជនជាប់ចោទ ដូចនេះតំណាងមហាអយ្យការសន្និដ្ឋាន សុំតម្កល់សាលក្រមព្រហ្មទណ្ឌ របស់សាលាដំបូងខេត្តព្រះវិហារដដែល។

## សេចក្តីសន្និដ្ឋានរបស់មេធាវី

រឿងក្តីនេះបានកើតឡើងនៅថ្ងៃទី១៦ខែកក្កដា ឆ្នាំ២០១០ កូនក្តីខ្លួនបានបញ្ជាក់ថា នៅថ្ងៃនោះគាត់គ្រាន់តែនៅចាំម៉ូតូទេ ហើយអ្នកដែលដៃដល់នោះគឺ បងប្រុសគាត់ ជាមួយកម្មករសំណង់ម្នាក់ទៀត មានឈ្មោះ [redacted] ធី ដែលជាអ្នកដៃដល់ ចូលទៅធ្វើសកម្មភាពប្លន់អ្នកលក់មាសក្នុងផ្សារ ខេត្តព្រះវិហារ ក្រោយពេលកើតហេតុកូនក្តីខ្លួនបានបញ្ជាក់ថា ដោយសារគាត់ភ័យពេកចង់មិនចង់ គាត់ត្រូវតែចូលរួម ជាមួយបងប្រុសរបស់គាត់ ហើយពេលនោះគាត់ក៏បានរត់ជាមួយគ្នា។ ដំបូងគេបានឲ្យលុយគាត់ចំនួនពីរលានរៀល ក្រោយមកចំនួនបួនលានរៀល និងគ្រឿងអលង្ការមួយចំនួនទៀតដែលត្រូវបានខាងបង ប្រគល់ទៅឲ្យប្រពន្ធ និងកូនគាត់ ជាក់ស្តែងក្នុងរឿងនេះ ប្រពន្ធគាត់ក៏បានត្រូវសាលាដំបូងឃុំខ្លួនមួយរយៈពេលដែរ, ក្រោយមកក៏សម្រេចឲ្យរួចផុតពីបទចោទ។ នៅពេលដែលកើតហេតុហើយគាត់រត់ជាមួយបងគាត់នោះ គាត់បានសុំបែកជាមួយបងប្រុសគាត់មួយដងហើយ ដូចគាត់បញ្ជាក់នៅក្នុងសវនាការ នៅពេលមកដល់ខេត្តសៀមរាប ចំណុចស្រុកដំដែកគឺគាត់បានចាកចេញពីបងគាត់ ហើយបងរបស់គាត់បានប្រគល់លុយឲ្យគាត់មួយចំនួន ហើយមូលហេតុដែលនាំឲ្យចាប់ខ្លួនគាត់ គឺដោយសារតែផ្ទះដែលគាត់នៅ គឺនៅជាប់នឹងផ្ទះប៉ូលីស ហើយរាប់អានជាមួយប៉ូលីសហើយ ប៉ូលីសមានលេខទូរសព្ទ័គាត់ ពេលគេស្រាវជ្រាវទៅដឹងថាគាត់នៅប៉ោយប៉ែត ទើបគេចាប់គាត់នៅទីនោះ ហើយគាត់ក៏បានឆ្លើយថា បើតាមចេតនាគាត់គឺគាត់មិនចង់ប្រព្រឹត្តបទល្មើសទេ មុននឹងឈានចូលដល់ការប្លន់ ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១០ នោះ គឺបងប្រុសគាត់បានប្រាប់គាត់អំពីគម្រោងការនោះ តែគាត់បានឃាត់ ប៉ុន្តែបងប្រុសគាត់នៅស្ងៀម។ ខ្លួនសូមសំណូមពរលោកប្រធាន ក៏ដូចជាលោកស្រី លោកចៅក្រមប្រឹក្សា ពិចារណាការប្រើប្រាស់មាត្រា៣ ច្បាប់ស្តីពីការស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ មកប្រើប្រាស់មាត្រា ៣៥៣, ៣៥៧ មកជាបទសមគំនិតវិញ ចំពោះទណ្ឌកម្មក៏ដូចគ្នាដែរ សូមមេត្តាពិចារណាតាមមាត្រា ៣៥៣, ៣៥៧ ដើម្បីផ្តល់នូវស្ថានសម្រាលទោសដល់កូនក្តីខ្លួន ដើម្បីឲ្យកូនក្តីខ្លួនមានលទ្ធភាពឆាប់ចេញពីពន្ធនាគារ ទៅរស់នៅជួបជុំជាមួយគ្រួសារ ប្រកបរបរសុចរិតវិញ។៥

ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ,

ក្រោយពីបានស្តាប់អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី,

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវី

ក្រោយពីបានពិភាក្សា វែកញែក ល្អិតល្អន់ តាមច្បាប់

## សាលាឧទ្ធរណ៍

## យល់ឃើញថា:

១. បណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១១ របស់ឈ្មោះ [redacted] ហូសាន់ ជាជនជាប់ចោទ ធ្វើក្នុងកំណត់ច្បាប់ តាមមាត្រា៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២. ជនជាប់ចោទ បានឆ្លើយថា មុនថ្ងៃកើតហេតុ បងខ្លួនឈ្មោះ [redacted] ប៊ុណ្ណា បានបបួលខ្លួនធ្វើសកម្មភាពប្លន់មែន តែខ្លួនមិនព្រម គាត់ក៏ទៅបបួលអ្នកផ្សេង។ នៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១០ ជាថ្ងៃកើតហេតុ បងខ្លួន និងឈ្មោះ [redacted] ធី ជិះម៉ូតូឌុបគ្នាទៅផ្សារ ឯខ្លួនជិះម៉ូតូខ្លួនតែម្នាក់ឯងទេ។ លុះទៅដល់ផ្សារ បងខ្លួនឲ្យខ្លួននៅចាំម៉ូតូ ហើយពួកគេទាំងពីរ នាំគ្នាដើរចូលទៅក្នុងផ្សារ។ នៅពេលពួកគេត្រឡប់មកវិញ ខ្លួនឃើញគេកាន់ថង់ខ្មៅ ទើបខ្លួនដឹងថា ពួកបងខ្លួនប្លន់គេ។

ក្រោយការប្លន់បានហើយ [redacted] ប៊ុណ្ណា បានឲ្យប្រាក់ខ្លួនចំនួន ៤.០០០.០០០រៀល ជាប្រាក់បានមកពីការលក់ទ្រព្យដែលប្លន់បាន។

៣. មានភស្តុតាងដាក់បន្ទុកលើជនជាប់ចោទឈ្មោះ [redacted] ហូសាន់ ពីបទ សមគំនិតក្នុងអំពើឃាតកម្មគិតទុកជាមុន ប្រព្រឹត្តនៅផ្សារកំពង់ប្រណាក ក្រុងព្រះវិហារ ខេត្តព្រះវិហារ កាលពីថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១០ បទល្មើសមានចែង និងឲ្យផ្តន្ទាទោសតាមមាត្រា៣ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ប៉ុន្តែដោយ គ្មានបណ្តឹងឧទ្ធរណ៍របស់តំណាងអយ្យការ គួររក្សាទុកនូវបទចោទ នៅដដែល។

៤. សាលក្រមព្រហ្មទណ្ឌលេខ ៦៨ ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១១ របស់សាលាដំបូងខេត្តព្រះវិហារ សម្រេចមានការខុសឆ្គង តែដោយបណ្តឹងឧទ្ធរណ៍ជារបស់ជនជាប់ចោទ គួរតម្កល់ទុកនៅដដែល។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី

១. ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១១ របស់ឈ្មោះ [redacted] ហូសាន់ ជាជនជាប់ចោទ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់។

២. តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៦៨ ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១១ របស់សាលាដំបូងខេត្តព្រះវិហារ ទុកជាបានការ ពេញទាំងមូល។

៣. បង្គាប់ឲ្យបន្តឃុំខ្លួនជនជាប់ចោទ។

សាលដីកានេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៤ ប្រកាសជាសាធារណៈ នៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ហូសាន់ និងមេធាវីការពារជនជាប់ចោទ, បើកផ្លូវសាទុក្ខ០១ខែ គិតចាប់ពីថ្ងៃប្រកាសសាលដីកានេះទៅ។

**សេចក្ដីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកម្លាំងគ្រប់ថ្នាក់គ្រប់តំណែង ជួយសហការអនុវត្តសាលដីកានេះឲ្យបាន សម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់។**

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា: [redacted] | ហត្ថលេខា [redacted], [redacted] | ហត្ថលេខា: [redacted] |

---

បានឃើញ

**ប្រធានសាលាឧទ្ធរណ៍**

ចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ, ថ្ងៃទី 12 ខែ 6 ឆ្នាំ ២០១៤

**ក្រឡាបញ្ជី**